**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402 🖷 9547 2763

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222 🖷 9558 4891
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព | ចូលរួម | លទ្ធផល | សហគមន៍ | សង្ឃឹម



ជំរាបមាតាបិតា/អាណាព្យាបាល,

យើងខ្ញុំរីករាយណាស់ដោយបានឃើញកុមារបានចុះចូលគ្នាល្អក្នុងឆ្នាំរៀនថ្មី។កុមារថ្នាក់មូលដ្ឋានពិតជាឆ្នើមមែន! ជាការគួរឲ្យស្ដាយដែលយើងត្រូវផ្អាការទៅលេងកំសាន្តនៅសួន Heatherton នាថ្ងៃទី៣/២,ក៏ប៉ុន្តែយើងមិនអាចជឿធាតុអាកាសនៃម៉េលប៊ុនបានឡើយ។ សង្ឃឹមថាយើងអាចទៅលេងនៅពេលក្រោយក្នុងឆ្នាំនេះ។

### កំណត់ប្រចាំថ្ងៃ:១៣/២/២០២៣

- ១៧/២: គោរពទង់ជាតិ:ម៉ោង៣:០០
- ២៨/២: ថ្ងៃគំរោងកម្មវិធីសិក្ស:កុមារសំរាកនៅផ្ទះ:
- ២៧/២: ក្រុមប្រឹក្សាសាលាប្រុំតាមរយៈវីបិក(webex): ម៉ោង៦:០០
- ០១/៣: កិច្ចប្រជុំនៃកុមារត្រូវការការគំទ្រពិសេស (SSG) (សាខាវ៉ាល្លី)
- ០៣/៣: គោរពទង់ជាតិ:ម៉ោង៣:០០ល្ងាច
- ០៦:៣: កិច្ចប្រជុំនៃកុមារត្រូវការការគំទ្រពិសេស (SSG) (សាខាខាងលិច)
- ០៨/៣: កិច្ចជួបពិភាក្សារវាងមាតាបិតានិងគ្រូ

### ការជួបជជែករវាងមាតាបិតាជាមួយនឹងគ្រូ:

សូមឆែកមើលកាបូបរបស់កុមារដើម្បីរកបណ្ណព័ត៌មានទាក់ទងនឹងសំណូមពរពេលម៉ោងមកជួបគ្រូរបស់កុមារដែលបានផ្ញើទៅផ្ទះ:កាលពីថ្ងៃពុធមុន។ យើងខ្ញុំសង្ឃឹមថានឹងបានជួបលោកអ្នកឲ្យបានច្រើនកុ:ករនៅថ្ងៃពុធទី៨/៣នេះ។
នេះគឺជាថ្ងៃរៀនធម្មតា,ព្រោះសាលាមានគ្រូជំនាញមកមើលកុមារនៅពេលល្ងាច។កុមារនឹងចេញទៅផ្ទះ:នៅម៉ោង៣:៣០ល្ងាច។

### សំណុំឯកសារសំរាប់សិស្សថ្នាក់ទី៦ឡើងថ្នាក់ទី៧:

ចំពោះគ្រួសារដែលមានកូនរៀននៅថ្នាក់ទី៦,លោកអ្នកនឹងបានទទួលសំណុំឯកសារសំរាប់ឡើងថ្នាក់ទី៧នៅដើមត្រីមាសទី២នេះ។Mrs Kenny ជាអ្នកបន្ទុកខាងការឡើងថ្នាក់នេះ។ដូច្នេះអ្នកគ្រូនឹងធ្វើយ៉ាងណាដើម្បីធានាថាមាតាបិតានឹងបានទទួលព័ត៌មានសំខាន់ៗទាំងឡាយដើម្បីជ្រើសរើសសាលាមធ្យមសិក្សាឲ្យឆ្នាំ២០២៤។

### Playgroup នៅសាខាខាងលិច:

បានចាប់ផ្ដើមកាលពីថ្ងៃអង្គារមុននៅសាខាខាងលិច។ឆ្នាំនេះ,នឹងចាប់ផ្ដើមលេងពីម៉ោង១០:០០-១២:០០ព្រឹក,ព្រោះបុគ្គលិកជំនួយមានកិច្ចការផ្សេងនៅពេលព្រឹក,ហើយមិនអាចមកមុនម៉ោង៩:៣០បាន។ពេលនេះនឹងផ្ដល់ឱកាសឲ្យអ្នកចាត់ចែងការលេងមានពេលរៀបចំដើម្បីអាចចាប់ផ្ដើមលេងនៅម៉ោង១០:០០បាន។សង្ឃឹមថានឹងបានឃើញគ្រួសារនៃសាលាស្ត្រីងប៉ាក់យើងមករួមក្នុងពេលលេងដោយឥតគិតថ្លៃនេះ។

### ថ្ងៃគំរោងកម្មវិធីសិក្សា:

យើងខ្ញុំនឹងមានកិច្ចប្រជុំសំរាប់ថ្ងៃគំរោងកម្មវិធីសិក្សាលើកទី២នៅថ្ងៃសុក្រទី ២៤ កុម្ភ:។យើងខ្ញុំនឹងបន្តធ្វើការជាមួយនឹងអ្នកជំនាញខាងគណិតសាស្ត្រក្នុងថ្ងៃនេះ។ថ្ងៃនេះកុមារឈប់សំរាកនៅផ្ទះ។បើមាតាបិតាត្រូវការអ្នកមើលថែរកុមារក្នុងថ្ងៃនេះ,យើងខ្ញុំបានស្គាល់ Kavita, ភេទស្រី,រស់នៅក្នុងតំបន់យើងហើយធ្វើការជាមួយនឹងសាលាក្រុងដែនឌីណុង។Kavita មានចុះឈ្មោះជាផ្លូវការនៅសាលាក្រុងហើយអាចមើលថែរកុមារក្នុងថ្ងៃគំរោងកម្មវិធីសិក្សនេះ។លេខទូរស័ព្ទរបស់Kavita គឺ 0425733406

### ការចូលនិវត្តនៃ Sally Simpson

ដូចបានរំឭកនៅក្នុងបណ្ណព័ត៌មានចុងឆ្នាំមុនរួចមកហើយថា Mrs Simpson នឹងឈប់ការងារពីក្រសួងអប់រំហើយថ្ងៃចុងក្រោយរបស់ Mrs Simpson គឺថ្ងៃសុក្រទី១០ ខែ កុម្ភ:។យើងទាំងអស់គ្នានឹងមិនបំភ្លេចទឹកមុខញញឹមរបស់គាត់ដែលធ្លាប់បានឃើញនៅជុំវិញសាលានោះឡើយ,ក៏ប៉ុន្តែយើងខ្ញុំក៏សង្ឃឹមថា Mrs Simpson នឹងរីករាយនឹងការចូលនិវត្តរបស់ខ្លួនដោយធ្វើដំណើរទេសចរណ៍និងលេងហ្គុល។ សាលាបានផ្ដល់ការងារដល់Fiona Frost ធ្វើការជំនួសនៅផ្នែកអភិបាលការិយាល័យនៃសាខាខាងលិច។បើជួបគាត់នៅការិយាល័យ,សូមស្វាគមន៍គាត់ដោយនិយាយពថាសួស្តី (hello ).

សូមឲ្យពីរសប្តាហ៍ទៅមុខនេះប្រកបដោយក្តីសុខនិងសប្បាយ។

Julie Fisher :
នាយកសាលា

សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Ardoch, IKEA, Woodleigh School, Officeworks & Resilience Project




## *កម្មវិធីហ្វឹកហ្វឺនជំនាញកីឡាបាល់ទាត់សំរាប់កុមារសាលា* (MiniRoos Kick-Off Schools Program )

• *ណែនាំកម្មវិធីបាល់ទាត់ប្រកបដោយការរីករាយនិងសុវត្ថិភាព-រចនាឡើងសំរាប់កីឡាករថ្មីលែមានអាយុពី៥-១១។ អាស្រ័យតាមចំនួនកុមារដែលចុះឈ្មោះចូលរួម,កម្មវិធីនឹងចែកចេញជា២ក្រុម-ក្រុមអាយុពី៥-៨ឆ្នាំនិងក្រុមអាយុពី៩-១១ឆ្នាំ។ ចំនួនកុមារច្រើនបំផុតក្នុង១ក្រុមគឺ២០-តិចបំផុតគឺ១០។*

• *រៀន១សប្តាហ៏ម្តងក្នុងរយៈពេល៤៥នាទីដើម្បីហ្វឹកហ្វឺនជំនាញតាមរយៈល្បែងលេងនិងបច្ចេកទេសក្នុងលក្ខណៈរួបរួមគ្នានឹងក្នុងបរិយាកាសដ៏កក់ក្តៅ។*

• *កីឡាករនិមួយៗមានពេលពេញបរិបូណ៌លេងបាល់,គោលបំណងចម្បងគឺហ្វឹកហ្វឺនមូលដ្ឋាននៃការស្ទាត់ជំនាញខាងចលនា។*

• *អ្នកចុះឈ្មោះថ្មីនិមួយៗនឹងបានទទួលស្បៀងចាប់ផ្តើមលេងបាល់ទាត់ជាដំបូងមីនីរូពីគណកម្មការបាល់ទាត់វិចតូរីយ៉ា*

• *គ្រូបង្ហាត់និមួយៗមានប័ណ្ណបញ្ជាក់បានឆែកពិនិត្យសន្តិសុខក្នុងពេលធ្វើការជាមួយកុមារ តើកម្មវិធីនេះផ្តល់នូវគុណប្រយោជន៏យ៉ាងដូចម្តេចខ្លះដល់កុមារ? ស្គាល់មិត្តភក្តិថ្មីហើយអភិវឌ្ឍន៏ជំនាញខាងសង្គម*

• *អភិវឌ្ឍគុណតម្លៃនៃការងារជាក្រុម,សហប្រតិបត្តិការ,ការលេងដោយយុត្តិធម៌,ហើយការចេះគោរពអ្នកដទៃ*

• *អភិវឌ្ឍសមត្ថភាពរបស់កុមារដើម្បីឲ្យចេះធ្វើការសម្រេចចិត្តបានឆាប់រហ័ស,ពេលប្រតិកម្មទៅលើបញ្ហាអ្វីមួយបានឆាប់រហ័សជាង*

• *រក្សាសុខភាពដោយចេះធ្វើសកម្មភាពនានា*

***ពេលនិងទីណា ?*** *នៅ៨សប្តាហ៏ដំបូងនៃត្រីមាសទី១ឆ្នាំ ២០២៣*

| | |
|---|---|
| Spring Parks PS<br>(Valley Campus)<br>27-39 Clarke Road<br>Springvale South VIC 3172 | *ពេលចាប់ផ្តើមនៃថ្ងៃអាទិត្យទាំងឡាយ* 12/2 : 10.30-11.15am<br>*បូករួមមាន៨ថ្ងៃអាទិត្យ-ចាប់ពីថ្ងៃអាទិត្យទី១២/២ ដល់ ថ្ងៃអាទិត្យទី២/៤-ឆ្នាំ២០២៣* |

***តម្លៃប៉ុន្មាន?*** *$១០០ចំពោះកុមារនិមួយៗ។*

***តើចុះឈ្មោះរបៀបណា?*** **How toregister?**

*អ្នកចូលថ្មី*: https://membership.mygameday.app/regoform.cgi?formID=101300&programID=61341

*សមាជិកចាស់* : https://membership.mygameday.app/regoform.cgi?formID=101304&programID=61342

*ដើម្បីពត៌មានបន្ថែមឬ* **contact us**, *សូមចូលគេហទំព័រ* : **Miniroos -Kingston Royals Futsal Club**



## ប្រាក់ជំនួយសំរាប់ការបោះជំរំ, កីឡា, ដំណើរសិក្សា (CSEF)

ប្រាក់នេះសំរាប់ជាជំនួយដល់គ្រួសារដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីជួយបង់ថ្លៃទៅបោះជំរំ,កីឡានិងដំណើរសិក្សា។

បើមាតាបិតាមានប័ណ្ណមាសអតីតយុទ្ធជន (Veterans Affairs Gold Card),ប័ណ្ណថែរទាំសុខភាព (Centrelink Health Care Card ), ប័ណ្ណនិវត្តន៏ (Pensioner Concession Card) ឬប័ណ្ណមានកូនចិញ្ចឹមបណ្តោះអាសន្ន,លោកអ្នកមានសិទ្ធិទទួល។

រដ្ឋក៏មានពិចារណាដល់ករណីពិសេសចំពោះជនភៀសខ្លួនឬគ្រួសារនៃជនភៀសខ្លួនផងដែរ។ចំនួនប្រាក់ទទួលបានសំរាប់ឆ្នាំនេះគឺ$១២៥សំរាប់គ្រួសារដែលមានសិទ្ធិទទួលនៅសាលាបឋមសិក្សា។

ប្រាក់នេះ,រដ្ឋនឹងផ្ញើតម្រង់មកសាលាដើម្បីចាយក្នុងសកម្មភាពបោះជំរំ,ធ្វើដំណើរកម្សាន្ត,និងកីឡាដែលជាសកម្មភាពផ្តល់ផលប្រយោជន៏ដល់កូនរបស់លោកអ្នក។ជាការសំខាន់ដែលប្រាក់នេះត្រូវចាយទៅលើសកម្មភាពកីឡា,បោះជំរំនិងដំណើរកម្សាន្តសំរាប់ឆ្នាំនេះដោយមិនត្រូវទុកឲ្យឆ្នាំក្រោយឡើយ។ប្រាក់នេះអាចចាយរួមជាមួយនឹងប្រាក់ជំនួយណាមួយដែលបានទទួលពីឆ្នាំមុន។

បើលោកអ្នកបានដាក់ពាក្យសូមកាលពីឆ្នាំមុនតាមរយសាលាយើង,លោកអ្នកមិនចាំបាច់ដាក់ពាក្យសូមនៅឆ្នាំនេះទេ,លុះត្រាតែមានការផ្លាស់ប្តូរស្ថានភាពគ្រួសារ។

ប្រសិនជាលោកអ្នកជាអ្នកដាក់ពាក្យជាលើកដំបូង, សូមទាក់ទងការិយាល័យសាលាតាមទូរស័ព្ទលេខ:
9546 6402 (West Campus) . 9547322(Valley Campus)
ហើយសួររកប័ណ្ណដាក់ពាក្យ។

លោកអ្នកក៏អាចយកប័ណ្ណនេះហើយស្វែងរកយល់បន្ថែមអំពីកម្មវិធីនិងសិទ្ធិទទួលលើគេហទំព័ររបស់ក្រសួងអប់រំនិងមូលនិធិដំណើរកម្សាន្ត,បោះជំរំនិងកីឡា(Department of Education and Training's Camps, Sports and Excursions Fund web page)

បើលោកអ្នកមិនច្បាស់អំពីចំណុចណាមួយ,សូមទាក់ទងនឹងការិយាល័យសាលា,ហើយសូមបញ្ជូនប័ណ្ណដែលបំពេញរួចហើយមកសាលាឲ្យបានរួសរាន់។

SPRING PARKS PRIMARY SCHOOL

## Playgroup ឆ្នាំ២០២៣ មកដល់ហើយ



## Playgroup:លេងដោយសេរី

មាតាបិតានិងកូនដែលរស់នៅក្នុងតំបន់យើងនឹងមាឱកាសស្វែងយល់អំពីអត្ថប្រយោជន៏នៃក្រុមលេងដោយឥតគិតថ្លៃ។
ក្រុមលេងថ្មីនេះបានចាប់ផ្តើមហើយ។

សូមអញ្ជើញមាតាបិតានិងកុមារក្នុងគ្រួសារមករួមក្នុងក្រុមលេងដែលបានរៀបចំជូននេះហើយដែលមានមូលដ្ឋាននៅសាខាខាងលិចនៃសាលាបឋមសិក្សាស្ព្រីងប៉ាក 24 Erica Street Springvale.

សកម្មភាពប្រចាំសប្តាហ៏មាន:គូរគំនូរ,ទឹករំអិល,ខ្សាច់,លេងទឹក,សំណង់,សត្វពាហនៈ,តន្ត្រីនិងអានរឿង,សូន្យរូបតុក្តានិងម្សៅ-ដើម្បីគាំត្រកូនចៅលោកអ្នកឲ្យចេះរាវរក,ប្រឌិតនិងធ្វើឲ្យលូតលាស់ការត្រិះរិះពិចារណា។

ដើម្បីពត៏មានពិស្តារ,សូមទូរស័ព្ទទៅកាន់សាលាបឋមសិក្សាស្ព្រីងប៉ាកតាមលេខ:
៩៥៤៦៦៤០២
ក្រុមលេង ( Playgroup )នឹងចាប់ផ្តើម
ពីម៉ោង១០:០០ព្រឹក-ម៉ោង១២:០០ព្រឹក
នេះគឺជាការផ្តើមគំនិតរួមរវាងសាលាបឋមសិក្សាស្ព្រីងប៉ាកនិងសាលាក្រុងដែនឌីណុង

## Sentral Parent Portal (ក្លោងទ្វារពត៌មានសំរាប់មាតាបិតា)

*សាលាយើងបានផ្តួចផ្តើមអនុវត្តគំនិតថ្មីមួយហៅថាក្លោងទ្វារពត៌មាននៃសិស្សនិងមាតាបិតា***(Student and Parent Portal)***ដើម្បីជួយលោកអ្នកមានតំណភ្ជាប់ជាមួយនឹងការសិក្សារអប់រំរបស់កុមារ។សិស្សទាំងឡាយបានទទួលពត៌មានពិស្តារស្តីពីរបៀបចូលប្រើឧបករណ៏នេះដែលបានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ២០២២។*
*សំរាប់សិស្សទើបចូលថ្មី,សាលានឹងផ្ញើសំបុត្រមួយទៅផ្ទះមានពត៌មានលំអិតស្តីពីរបៀបចូលប្រើ។ប្រសិនជាលោកអ្នកមិនទាន់បានទទួលសំបុត្រនេះទេឬមិនអាចចូលប្រើបាន,សូមទាក់ទងនឹងគ្រូរបស់ កុមារឬការិយាល័យនៅសាខាទាំងពីរ។លក្ខណៈពិសេសនៃក្លោងទ្វារពត៌មាននេះគឺផ្តល់ពត៌មានទៀងទាត់,ពត៌មានពីវត្តមាន/អវត្តមានរបស់កុមារ,ផ្ញើសារតម្រង់ទៅគ្រូរបស់កុមារ,ចម្លងទុកអវត្តមានរបស់កុមារ,ហើយនឹងលទ្ធភាពអាចចូលមើលរបាយការណ៍របស់កុមារលើអ៊ិនធើណែត។ចាប់ពីឆ្នាំ២០២៣ទៅ,របាយការណ៏របស់សិស្សនឹងមិនបានបោះពុម្ពចេញដូចមុនទៀតឡើយ។ម្ល៉ោះហើយ,មាតាបិតាត្រូវ ចូលក្នុងក្លោងទ្វារពត៌មាន*(Parent Portal)*ដើម្បីមើល។សូមស្នើថា,មាតាបិតាគួរដកយករបាយការណ៏របស់កុមារ* **(Download)** *ពីកុមព្យូទ័រហើយរក្សាទុកកាលណារបាយការណ៏នេះបានផ្សាយចេញដើម្បីងាយចូលមើលនៅថ្ងៃក្រោយ។*
*ខ្ញុំសង្ឃឹមថាលោកអ្នកនឹងឃើញពីផលប្រយោជន៏នៃឧបករណ៏នេះដែលបានចាត់ចែងឡើងដើម្បីជួយគាំទ្រសិស្សានុសិស្សនៃសាលាបឋមសិក្សាស្ព្រីងប៉ាក។ពត៌មានបន្ថែមអំពីវេទិការនេះអាចរកឃើញនៅទីនេះ:* **https://www.sentral.com.au/parents.**
*តំណភ្ជាប់នៃក្លោងទ្វារពត៌មានសំរាប់មាតាបិតាគឺ* **https://sentral.springparksps.vic.edu.au/portal2/#!/login.**
*ដើម្បីជួយលោកអ្នកទើបចាប់ផ្តើមចូលប្រើ,យើងខ្ញុំបានស្ថាបនាសេចក្តីណែនាំចំនួនពីរទំព័រដែលអាចចូលតម្រង់ទៅគេហទំព័ររបស់យើងខ្ញុំ:* 2-page user guide which can be accessed through our website *បើលោកអ្នកត្រូវការជំនួយគាំទ្របន្ថែម,សូមទាក់ទងនឹងគ្រូរបស់កុមារឬបុគ្គលិកការិយាល័យនៃសាខាទាំងពីរ*.

**Trish Harry**

## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 1 | Week 2 |
|---|---|---|
| FA | Amy | Rayen & Varaden |
| 1/2 A | Lakshya | Aden |
| 1/2 B | Sabal | Abby |
| 3/4 A | Whole Grade | hayden |
| 3/4 B | Whole Grade | Khorint |
| 5/6 A | Wiliam | Rachel |
| 5/6 B | Alexandrea | Kelvin |
| Art | Lakshya 1/2A | Allie 3/4A |
| PE | Morokot 3/4B | Abby 1/2B |
| Spani- | Cassidy 3//4A | Laksya |

### VALLEY CAMPUS

| Grade | Week 1 | Week 2 |
|---|---|---|
| FA | Jaydeen | Krystal |
| 1/2 L | Xavier | Alicia |
| 1/2 M | Branden | Isha |
| 3/4 L | Keivin | Adrian |
| 3/4 M | Atiya | Rebel |
| 5/6 L | Halitt | Yi Lian |
| 5/6 M | Bryceson | Muaz |
| Art | Adrian | Muiz |
| PE | Ben | Alycia |
| Span- | William | Aleeshiya |